ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ
លេខ : ៧៥៦ មស.ក្រ

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែមីនា ឆ្នាំ ២០១៧

**រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ**
**គោរពជូន**
**ឯកឧត្តមប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**កម្មវត្ថុ** :-ស្តីពីសំណើសុំរក្សាទុកបៀវត្សមូលដ្ឋាន និងប្រាក់បំណាច់មុខងារ ព្រមទាំងអត្ថប្រយោជន៍ផ្សេងៗទៀត អនុលោមបទប្បញ្ញត្តិជាធរមាន របស់មន្ត្រីរាជការដែលជាមន្ត្រីជាប់កិច្ចសន្យាបម្រើការងារនៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**យោង** :-អនុក្រឹត្យលេខ ១០៦ អនក្រ.បក ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃអគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។
-ចំណារឯកភាពរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១៧ ។
-ដីកាបញ្ជូនលេខ ២៩៨ ខន/០១៧ ចុះថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៧ របស់ខុទ្ទកាល័យសម្តេចអគ្គ-មហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី ។
-លិខិតលេខ ០៧៤ គ.ជ.ប ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តមប្រធានមេត្តាជ្រាបថា ដោយមានចំណារឯកភាពពី**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដើម្បីរក្សាផលប្រយោជន៍ជូនមន្ត្រីរាជការដែលទៅបម្រើការងារជាមន្ត្រីជាប់កិច្ចសន្យានៅ គ.ជ.ប នៅក្នុងយុទ្ធការរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ សង្កាត់ អាណត្តិទី ៤ ឆ្នាំ ២០១៧ ខាងមុខនេះ ក្រសួងមុខងារសាធារណៈ យល់ព្រមរក្សាទុកបៀវត្សមូលដ្ឋាន និងប្រាក់បំណាច់មុខងារ ព្រមទាំងអត្ថប្រយោជន៍ផ្សេងៗទៀត អនុលោមបទប្បញ្ញត្តិជាធរមាន ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមប្រធានមេត្តាជ្រាប និងទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ ។

**ចម្លងជូន**
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- គ្រប់សាលារាជធានី ខេត្ត
  "ដើម្បីជូនជ្រាប"
- ឯកសារ-កាលប្បវត្តិ

**ពេជ្រ ប៊ុនធិន**